# សិក្ខាសាលាផ្សព្វផ្សាយស្តីពី
# ភាគព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល
# រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣
# ទីកន្លែង៖ សណ្ឋាគារសុខា

អ្នកចូលរួមសរុប៖ ៤០៨នាក់ មកពី ២៦៤សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

## 1. មតិស្វាគមន៍ ដោយ លោកស្រី ស៊ិន ពុទ្ធារី នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក

យោងតាមស្មារតី សេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ដែលមានឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនាយកដ្ឋានពន្ធដារ ជាសហប្រធាន និង លោកស្រី ស៊ិន ពុទ្ធារី នាយិកាប្រតិបត្តិនៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ជាសហប្រធានតំណាងពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលទើបតែធ្វើបច្ចុប្បន្នភាពកាលពីថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០២១។

ចាប់តាំងពីការបង្កើតក្រុមការងារចម្រុះ ៤ ឆ្នាំមកនេះ ក្រុមការងារចម្រុះ បានប្រឹងប្រែងធ្វើការងារជាមួយគ្នាយ៉ាងសកម្ម។ អង្គការសង្គមស៊ីវិល សូមស្វាគមន៍ និងទទួលស្គាល់នូវភាពជាអ្នកដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើកំណែទម្រង់ និងរដ្ឋាភិបាលសារពើពន្ធ សំដៅដល់ការធានាឱ្យបាននូវចេរភាពកំណើនរយៈពេលវែង ដោយបង្កើតនូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ ប្រព័ន្ធការងារ ដើម្បីពង្រឹងដំណើរការប្រព័ន្ធឱ្យល្អប្រសើរ ធានានូវតម្លាភាព ស័ក្តិសិទ្ធិភាព ភាពងាយស្រួលព្រមទាំងឆាប់រហ័សទាន់ពេលវេលា។

អង្គការសង្គមស៊ីវិល សូមស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះឥរិយាបទឆ្លើយតបជាវិជ្ជមាន វប្បធម៌នៃការពិភាក្សា និងការបណ្តុះបណ្តាលវប្បធម៌នៃការបង់ពន្ធ និងការលើកកម្ពស់អំពីចំណេះដឹងពន្ធដារដល់អង្គការសង្គមស៊ីវិល។ ជាពិសេសការពិភាក្សាដោយបើកចំហរ ប្រកបដោយវិជ្ជាជីវៈ និងស្មារតីភាពជាដៃគូនៃក្រុមការងារចម្រុះទាំងមន្ត្រីបច្ចេកទេស និងពាក់កណ្តាលបច្ចេកទេស និងថ្នាក់ដឹកនាំ។

កាលពីខែមេសា ឆ្នាំ២០២២នេះ យើងមានកិច្ចប្រជុំក្រុមការងារចម្រុះលើកដំបូងបន្ទាប់ពីការរីករាលដាលជំងឺកូវីដ១៩ ក្នុងរយៈពេល ៤ឆ្នាំមកនេះ អង្គការ គសក បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ដោយមានកិច្ចសហការយ៉ាងល្អពីអគ្គនាយកដ្ឋានពន្ធដារក្នុងការគាំទ្រ និងផ្តល់មន្ត្រីជំនាញជាវាគ្មិនកិត្តិយសនូវគ្រប់សិក្ខាសាលាដែលបានរៀបចំជាសរុបមានចំនួន ១២ សិក្ខាសាលា ដែលមានអ្នកចូលរួមសរុប ២៥៤០ នាក់ (៦០ % ជាស្ត្រី) ដែលជាមធ្យមមានអ្នកចូលរួមប្រមាណ ២០០ នាក់ ក្នុងសិក្ខាសាលា ឬវេទិកានីមួយៗ។

នៅក្នុងឯកសារទស្សនទាន និងគោលនយោបាយទាំងអស់បានរៀបរាប់ជូន តែងតែបានរំលេចនូវតួអង្គអភិវឌ្ឍន៍ទាំងអស់ ដែលមិនអាចខ្វះបាន ហើយក្នុងនោះមានរួមបញ្ចូលតួនាទីរបស់អង្គការសង្គមស៊ីវិលផងដែរ។

យោងតាមរបាយការណ៍សម្រង់ទិន្នន័យ ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាជិកអង្គការ គ.ស.ក ជាង១៩០ ស្ថាប័នបានបង្ហាញថាទឹកប្រាក់ចន្លោះ ៥០០ ទៅ ៦០០ លានដុល្លាក្នុងមួយឆ្នាំៗត្រូវបានចំណាយក្នុងការចូលរួមចំណែកសម្រាប់ការងារអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។

យោងតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃមានអង្គការសង្គមស៊ីវិលជាង៥០០០ ស្ថាប័ននៅក្នុងប្រទេសកម្ពុជា ប្រាកដណាស់ថា ចំនួនទឹកប្រាក់សរុបនឹងមានចំនួនច្រើនរយលានដុល្លាក្នុងមួយឆ្នាំៗដល់ការអភិវឌ្ឍនៅប្រទេសកម្ពុជា។

- សំណូមពរឱ្យមានការបណ្តុះបណ្តាល ជាពិសេសសម្រាប់អង្គការតូចៗនៅតាមខេត្តនីមួយៗ
- ស្នើឱ្យមានកិច្ចប្រជុំក្រុមការងារចម្រុះរវាងសមាគម និងអង្គការសង្គមស៊ីវិល និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដោះស្រាយបញ្ហាបច្ចេកទេស និងស្វែងរកយុទ្ធិសាស្ត្រមួយចំនួនទៀត។
- របាយការណ៍ស្ទង់មតិដែលបានធ្វើឡើងដោយអង្គការសង្គមស៊ីវិលកន្លងមក ដែលមានលទ្ធផល និងអនុសាសន៍ល្អៗ នឹងដាក់ជូន ចែករំលែកដល់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការសម្រួលនីតិវិធី ឬក្របខណ្ឌគតិយុទ្ធនានា។

## 2. សន្ទរកថាបើកសិក្ខាសាលាដោយ ឯ. កែន សម្បត្តិ អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការ គ.ស.ក ដែលបានចូលរួមរៀបចំ អញ្ជើញអង្គការសង្គមស៊ីវិល និងចូលរួមថ្លែងសន្ទរកថាស្វាគមន៍ និង លោក សេង តុលា អគ្គនាយរងនៃនិយ័តករគណនេយ្យ និងសវនកម្ម មន្ត្រីពន្ធដារ។

សិក្ខាសាលានេះរៀបចំឡើង ដើម្បីអនុវត្តតាមមាត្រា ៩១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ។

មាត្រា ៩១ នៃច្បាប់ស្តីពីសារពើពន្ធ បានចែងថា « អ្នកជាប់ពន្ធមានសិទ្ធិទទួលព័ត៌មានជាប្រចាំអំពីដំណើរការនៃប្រព័ន្ធពន្ធដារ ហើយនិងនីតិវិធីនៃការកំណត់ពន្ធដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់សារពើពន្ធ» ដែលចែងអំពីការផ្សព្វផ្សាយ និងពន្យល់ណែនាំច្បាប់ពន្ធដារ។

សិក្ខាសាលានាថ្ងៃនេះ ជាសិក្ខាសាលាដ៏ធំមួយដែលរៀបចំសម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ២០២៣ ចាប់តាំងពីបានបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈប្រកាសលេខ១០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រជាពលរដ្ឋមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ថវិកាដែលបានពីការប្រមូលពន្ធយកទៅប្រើប្រាស់លើសេវាសាធារណៈជូនប្រជាពលរដ្ឋវិញ ក្នុងនោះថវិកាមួយចំនួនត្រូវបានរក្សាទុកជាទុនបម្រុងរបស់រដ្ឋ។ ជាក់ស្តែងក្នុងពេលជួបនូវិបត្តិកូវីដ១៩ រដ្ឋាភិបាលបានយកថវិកាទាំងនោះ ដើម្បីទិញវ៉ាក់សាំងជូនប្រជាពលរដ្ឋ ប្រជាពលរដ្ឋបានទទួលវ៉ាក់សាំងកូវីដ១៩ ដោយឥតបង់ថ្លៃរបស់ប្រជាពលរដ្ឋក្នុងបរិបទកូវីដ និងការឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រជាដើម។

ដើម្បីផ្តល់សេវាជូនអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកពន្ធ ក៏ដូចជាផ្តល់សេវាសាធារណៈពាក់ព័ន្ធជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ មន្ត្រីសាធារណៈត្រូវមានលក្ខណៈសម្បត្តិសំខាន់ ៤ យ៉ាងគឺ៖

**មន្ត្រីសាធារណៈ**

- មានឥរិយាបទទន់ភ្លន់ រួសរាយរាក់ទាក់ និងផ្តល់សេវាប្រកបដោយឆន្ទៈការងារខ្ពស់
- មានសិល្បៈនៃការពន្យល់ និងដោះស្រាយបញ្ហា

- មានក្រមសីលធម៌វិជ្ជាជីវៈ តម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តការងារ
- មានសមត្ថភាពពេញលេញទាំងសមត្ថភាពវិជ្ជាជីវៈ ទាំងសមត្ថភាពបទប្បញ្ញត្តិ ទាំងសមត្ថភាពផ្នែកបទពិសោធន៍ការអនុវត្តការងារ

**អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកពន្ធ ឬពលរដ្ឋល្អ ត្រូវមានលក្ខណៈសម្បត្តិសំខាន់ៗ៤យ៉ាងគឺ**

- មានសីលធម៌ក្នុងសង្គម
- គោរពបានខ្ជាប់ខ្ជួនតាមច្បាប់ និងបទប្បញ្ញត្តិច្បាប់ជាធរមាន
- ខិតខំស្វែងរកចំណេះដឹង ចំណេះធ្វើមកដាក់ក្នុងខ្លួន និងខិតខំធ្វើបច្ចុប្បន្នភាពចំណេះដឹងទាំងនោះជាប្រចាំ
- ចេះសាមគ្គីភាពគ្នា គោរពសិទ្ធិគ្នាទៅវិញទៅ និងចូលរួមសកម្មលើកស្ទួយសង្គម

**គោលការណ៍ធំៗ៣៖**

- ចីរភាពនៃកំណើនចំណូល
- ការប្រកួតប្រជែងដោយស្មើភាព
- ធានានូវសមធម៌

**រដ្ឋាភិបាលមានតួនាទី៤សំខាន់**

- រៀបចំហេដ្ឋារចនាសម្ព័ន្ធ
- រៀបចំសេវាសង្គមកិច្ច (បសស)
- បែងចែងធនធានប្រកបដោយសមធម៌

គោលដៅលើកម្ពស់ការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានកាន់តែប្រសើរ អគ្គនាយកដ្ឋានពន្ធដារបានធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធតាមរយៈការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយបានដាក់ឱ្យអនុវត្តបច្ចេកវិទ្យាទំនើបមួយចំនួនដូចជា E-VAT, E-FILLING, E PAYMENT, GDT-LIVECHART,E-REGISTRATION,E-TAX SERVICE ជាដើម និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន (APPLICATION) ជាច្រើនទៀត គោលដៅគ្រប់គ្រងទិន្ន័យពន្ធដារឱ្យបានគត់មត់ និងសេវាជូនអ្នកជាប់ពន្ធឱ្យបានកាន់តែល្អប្រសើរ ឆាប់រហ័ស មានតម្លាភាព គណនេយ្យភាព និងភាពងាយស្រួលក្នុងការបង់ពន្ធ។

បុរេសកម្ម៖ ដាក់ចេញនូវប្រព័ន្ធបច្ចេកវិទ្យាស្របតាមយុគ្គសម័យឧស្សាកម្មបច្ចេកវិទ្យា ដែរសម្រួលដល់អ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក។ ពន្ធដារបានរៀបចំសិក្ខាសាលារាប់ពាន់ក្នុងមួយឆ្នាំៗ ដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធ ឲ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានល្អ។

ត្រឹមខែមករា ឆ្នាំ២០២៣ ការប្រមូលពន្ធបានជាង ៣០០លានដុល្លារ ៨.៤% លើសមធ្យមភាគប្រចាំខែត្រឹម ៨.៣៣% បើទោះបីក្នុងបរិបទការធ្លាក់ចុះសេដ្ឋកិច្ចដោយសារកូវីដ សង្គ្រាមរុស្សីនិងអ៊ុយក្រែន។

ទោះបីជាក្រសួងមហាផ្ទៃមានអង្គការសមាគមជិត ៦០០០ បានចុះបញ្ជីក៏ដោយ តែមានស្ថាប័នខ្លះមិនមានសកម្មភាព តែយើងមិនទាន់បានធ្វើបច្ចុប្បន្នភាព។ បើយើងធ្វើបច្ចុប្បន្នភាពចំនួននេះ មិនអាចដល់៥០០០ស្ថាប័នទេ។

សូមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមអនុវត្តកាតព្វកិច្ចទាំងអស់គ្នា ប្រសិនបើមិនចបាន អនុវត្តពេលនេះ ក៏ត្រូវអនុវត្តនៅពេលក្រោយដែរ។ តែនៅពេលក្រោយនឹងត្រូវរងការពិន័យ និងទោសទណ្ឌ ហើយអ្នកមិន

អាចនិយាយថា ខ្ញុំមិនដឹងអំពីកាតព្វកិច្ចសារពើពន្ធនេះទេ។ ហើយដើម្បីទទួលបានជោគជ័យ អភិបាលកិច្ចល្អត្រូវតែមានទ្វេរភាគី ទាំងអគ្គនាយដ្ឋានពន្ធដារ និងអ្នកជាប់ពន្ធ។

### 3. កាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយ លោក ប៉ូ ពិសិដ្ឋ អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម

ព័ត៌មានលម្អិតពីបទបង្ហាញ សូមចូលទៅឧបសម្ព័ន្ធទី ២

**ប្រកាស ៤៦៤**

- គ្រប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែចុះបញ្ជីពន្ធដារ តែបើមិនចុះបញ្ជីទេ គឺខុសច្បាប់ហើយ
- បន្ទាប់ពីចុះបញ្ជីហើយត្រូវៈ
  - ពន្ធលើប្រាក់បៀវត្ស កាត់ទុក ប្រចាំខែ
  - លិខិតប្រកាសពន្ធប្រចាំឆ្នាំ (មិនឲ្យហួសថ្ងៃ៣១ ខែមីនា នៃឆ្នាំបន្ទាប់)

**សេចក្តីណែនាំ ៣០៣៣**

- សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ទាំងឡាយណាដែលមានសកម្មភាពអាជីវកម្មដោយឡែក មិនស្ថិតក្នុងគោលដៅសុទ្ធសាធត្រូវៈ
  - ចុះបញ្ជីពន្ធដាច់ដោយឡែក និងត្រូវប្រាក់សពន្ធ
    - ពន្ធលើប្រាក់ចំណូល
    - ពន្ធលើប្រាក់បៀវត្ស
    - ពន្ធកាត់ទុក
    - ពន្ធអាករដទៃទៀត
- សម្រាប់សកម្មភាពអាជីវកម្មដាច់ដោយឡែក ត្រូវធ្វើចំណាត់ថ្នាក់ទៅតាមផលរបរ (អ្នកជាប់ពន្ធតូច មធ្យម និងធំ)
- សម្រាប់អង្គការ ដែលមានសកម្មភាពសប្បុរសធម៌ផង និងសេដ្ឋកិច្ចផង ពន្ធដារតម្រូវឲ្យអង្គការធ្វើការញែកឲ្យដាច់ពីគ្នា ទ្រព្យសកម្ម បុគ្គលិក ...។ល។ ដូចនេះអង្គការត្រូវធ្វើការប្រកាសពន្ធស្ថាប័នពីរដាច់ពីគ្នា។

### 4. ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដោយ លោក សុធី គីរី មន្ត្រីនៃនាយដ្ឋានបច្ចេកវិទ្យាព័ត៌មាន

ព័ត៌មានលម្អិតពីបទបង្ហាញ សូមចូលទៅឧបសម្ព័ន្ធទី ៣

### 5. កាតព្វកិច្ចគណនេយ្យនិងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយ លោក លី កុសល ប្រធាននាយកដ្ឋានគតិយុត្ត និងអនុលោមភាពស្តីទី នៃនិយ័តករគណនេយ្យនិងសវនកម្ម

ព័ត៌មានលម្អិតពីបទបង្ហាញ សូមចូលទៅឧបសម្ព័ន្ធទី ៤

## 6. វេទិកាសំណួរ-ចម្លើយ

វាគ្មិនៈ

- តំណាងពីនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- តំណាងពីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- តំណាងពីនិយ័តករគណនេយ្យនិងសវនកម្ម

## 7. មតិបិទកម្មវិធី ដោយ តំណាងអគ្គនាយកដ្ឋានពន្ធដារ

## ឧបសម្ព័ន្ធៈ

1. របៀបវារៈសិក្ខាសាលា — 1. របៀបវារៈកម្មវិធីសិក្ខាស
2. បទបង្ហាញស្តីពីកាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដោយ លោក ប៉ូ ពិសិដ្ឋ — 2. កាតព្វកិច្ចសារពើពន្ធរ
3. បទបង្ហាញស្តីពីប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដោយ លោក សុធី គីរី — 3. TOI e-filing portrait V1.1.3 Update.pdf
4. បទបង្ហាញស្តីពី 5. កាតព្វកិច្ចគណនេយ្យនិងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយ លោក លី កុសល — 4.កាតព្វកិច្ចគណនេយ្យ _និងសវនកម្ម_សម្រាប់
5. ប្រកាស៤៦៤ៈ ការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល — Prakas-464_taxation-for-ngos_kh__12.04.20
6. សេចក្តីណែនាំ ៣០៣៣ៈ ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល — GDT_Instruction_NGO_Registration 3033.pd
7. ប្រកាស ០០៩ៈ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស — Prakas 009 MEF Taxpayer Threshold -
8. ប្រកាស ១៩៣ៈ វិធាន និងនិតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ — Prakas 193 MEF - Prakas Patent Tax.pdf

# ទេទិការសំណួរ & ចម្លើយ

1. តើការទិញសម្ភារៈ IT ពីបរទេស (IT license) ត្រូវបង់ពន្ធយ៉ាងដូចម្តេច?

ចម្លើយ៖ ក្នុងនាមជា NGO ស្ថាប័នប្អូនមិនអាច Claim Reverse Charge ត្រឡប់មកវិញបានទេ។ ដូចនេះក្នុងករណីស្ថាប័នប្អូនបានទិញ (ឧ. Zoom account) ស្ថាប័នត្រូវកាតព្វកិច្ចបង់ អតប ១០% និងត្រូវបង់កាត់ទុក ១៤% បន្ថែមទៀត។

2. សំណួរ (ACAR)៖ ក្នុងឆ្នាំ ២០២២ ស្ថាប័នរបស់ខ្ញុំ បានដាក់លិខិតស្នើសុំប្រើប្រាស់ភាសារបរទេសសម្រាប់របាយការណ៍ ឆ្នាំ២០២១រួចហើយ និងបានដាក់ចូលក្នុងប្រព័ន្ធរួចរាល់ហើយដែរ។ នៅពេលដាក់របាយការណ៍ ២០២២ តើតម្រូវឱ្យដាក់លិខិតស្នើសុំប្រើភាសារខ្មែរទៀតទេ? ហើយសម្រាប់ឯកសារគាំទ្រ ( កុងត្រាជាមួយទីប្រឹក្សា) ដែលធ្វើឡើងជាភាសាបរទេស តើតម្រូវឲ្យធ្វើឡើងវិញជាភាសាខ្មែរឬទេ?

ចម្លើយ៖

**សូមបញ្ជាក់ថា៖** ការដាក់លិខិតស្នើសុំប្រើប្រាស់ភាសាបរទេស អនុញ្ញាតឲ្យប្រើតែក្នុងប្រព័ន្ធគណនេយ្យតែប៉ុណ្ណោះ។ សម្រាប់របាយការណ៍ហិរញ្ញវត្ថុ ភាសាផ្លូវការមានតែមួយប៉ុណ្ណោះគឺភាសាខ្មែរ តែអ្នកអាចប្រើភាសាអមជាបរទេស តែមិនអាចយកភាសាបរទេស មកជំនួសភាសាខ្មែរនោះទេ។

**សម្រាប់ឯកសារគាំទ្រ (កុងត្រាទីប្រឹក្សាជាភាសាបរទេស)** ACAR មិនតម្រូវឱ្យធ្វើកុងត្រាថ្មីជាភាសាខ្មែរទេ ប្រសិនបើកុងត្រានោះនៅមានសុពលភាព ដោយគ្រាន់តែធ្វើការបកប្រែជាភាសាខ្មែរ និងវាយត្រាបញ្ជាក់តាមបែបបទរដ្ឋបាលឲ្យបានត្រឹមត្រូវ និងដាក់ភ្ជាប់មកជាមួយនៅពេលដាក់របាយការណ៍ឆ្នាំថ្មី។

3. សំណួរ (GDT)៖ ស្ថាប័នរបស់ខ្ញុំបានបង្កើត account log in សម្រាប់ប្រកាសពន្ធប្រចាំឆ្នាំ TOI - ២០២១ តើស្ថាប័នខ្ញុំត្រូវការបង្កើតគណនីថ្មី សម្រាប់ការប្រកាសពន្ធ TOI ឆ្នាំ ២០២២ ឬ អាចប្រើគណនីចាស់ឆ្នាំ២០២១បាន?

ចម្លើយ៖ ស្ថាប័នប្អូនអាចប្រើប្រាស់គណនីចាស់ដដែល គ្រាន់តែយើងបង្កើតលិខិតប្រកាសពន្ធថ្មីសម្រាប់ឆ្នាំ ២០២២។

4. សំណួរ៖ អត្រាប្តូរប្រាក់មធ្យមភាគ តើគណនាសម្រាប់អ្វី?

ចម្លើយ៖ ការប្រើប្រាស់អត្រាប្តូរប្រាក់ជាមធ្យមសម្រាប់គណនី P&L ។

5. សំណួរ (ACAR)៖ ប្រសិនបើស្ថាប័នរបស់ខ្ញុំបានដាក់របាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធ e-filling រួចហើយ តើតម្រូវឲ្យដាក់របាយការណ៍ហិរញ្ញវត្ថុ (ជា Hard copy) ទៅ ACAR ទៀតឬទេ?

ចម្លើយ៖

ប្រសិនបើស្ថាប័នប្អូន បានដាក់របាយការណ៍ហិរញ្ញវត្ថុមក (ACAR) តាមប្រព័ន្ធ E-Filing រួចហើយ ស្ថាប័នប្អូនមិនតម្រូវឱ្យដាក់របាយការណ៍ហិរញ្ញវត្ថុជា Hard Copy មក (ACAR) ទៀតទេ។ សូមបញ្ជាក់ថា (ACAR) ទទួលរបាយការណ៍ហិរញ្ញវត្ថុតាមរយៈប្រព័ន្ធ E-Filing តែមួយគត់ មិនទទួល Hard Copy ទេ។

សូមបញ្ជាក់ជាថ្មីម្តងទៀតថា ការដាក់របាយការណ៍មក (ACAR) គឺអនុវត្តស្របទៅតាមច្បាប់គណនេយ្យ និងសវនកម្ម។ វាមិនមានន័យថា ការដាក់របាយការណ៍មក (ACAR) ទៅជំនួសនឹងការដាក់របាយការណ៍របស់ស្ថាប័នប្អូនទៅក្រសួងផ្សេងទៀតទេ។ ដូចនេះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវដាក់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន៖

- ក្រសួងមហាផ្ទៃ (បំណាច់ខែកុម្ភៈ)
- ក្រសួងការបរទេស (បំណាច់ខែកុម្ភៈ)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (បំណាច់ខែកុម្ភៈ)
- និយ័តករគណនេយ្យនិងសវនកម្ម តាមប្រព័ន្ធ E-Filing
    - អង្គភាពមិនរងសវនកម្មឯករាជ្យ៖ ៣ខែ ១៥ថ្ងៃ
    - អង្គភាពរងសវនកម្មឯករាជ្យ៖ ៦ខែ ១៥ថ្ងៃ
- អគ្គនាយដ្ឋានពន្ធដារ-ប្រកាសពន្ធប្រចាំឆ្នាំតាមប្រព័ន្ធ ToI E-Filing (បំណាច់ខែមីនា)

6. សំណួរ (GDT)៖ ប្រសិនបើមាន ការធ្វើបច្ចុប្បន្នភាព ឬ ការកែតម្រូវផ្សេងៗលើព័ត៌មានស្ថាប័ន តើត្រូវការឯកសារតម្រូវអ្វីខ្លះ? តើត្រូវបង់សេវាប៉ុន្មាន?

ចម្លើយ៖ ស្ថាប័នរបស់ប្អូនត្រូវស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានស្ថាប័ន ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់បច្ចុប្បន្នភាព ដាក់មកស្នាក់ការកណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារ និង តម្រូវឱ្យបង់សេវារដ្ឋបាលចំនួន ២០ ម៉ឺនរៀល ។

7. សំណួរ៖ ចំពោះសេចក្តីណែនាំលេខ ៣០៣៣ ស្តីពីការចុះបញ្ជីអាជីវកម្មដោយឡែកសម្រាប់ NGO ជាក់ស្តែង NGO របស់ខ្ញុំ មានបើកការបណ្តុះបណ្តាលរកចំណូលបានតិចតួច ដែលចំណូលនោះត្រូវបានប្រើប្រាស់សម្រាប់គាំទ្រប្រតិបត្តិការរបស់ស្ថាប័នមិនបានបម្រើឲ្យផលប្រយោជន៍បុគ្គលណាម្នាក់នោះទេ ហើយចំណូលនោះតិចជាងលក្ខខណ្ឌពន្ធតូចទៅទៀត។ តើស្ថាប័នរបស់ខ្ញុំតម្រូវឲ្យចុះបញ្ជីអាជីវកម្មដោយឡែកឬទេ?

ចម្លើយ៖ ទោះជាចំណូលតិចជាង (២៥០ លាន ≈ 62,500$) ឱ្យ រាល់ចំណូលបន្ទាប់បន្សំទាំងអស់ តែមានសកម្មភាពសេដ្ឋកិច្ចដោយឡែក ស្ថាប័នត្រូវមានកាតព្វកិច្ចចុះបញ្ជីអាជីវកម្មដោយឡែក ទោះបីជាមិនមានពន្ធត្រូវប្រកាសក៏ដោយ។ ស្ថាប័នត្រូវតែមកចុះបញ្ជីអាជីវកម្មដោយឡែក តែស្ថាប័នមិនតម្រូវឲ្យស្នើសុះប៉ាតង់ និងអនុវត្តកាតព្វកិច្ចអ្វីផ្សេងនោះទេ ដោយគ្រាន់តែប្រកាសពន្ធលើប្រាក់ចំណូល។ ដោយសារប្រាក់ចំណូលដែលរកបាន យកមកបម្រើឲ្យស្ថាប័ន/សង្គម ស្ថាប័នអាចស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលមកអគ្គនាយកដ្ឋានពន្ធដារ (តម្រូវដាក់ពាក្យស្នើសុំ) អគ្គនាយដ្ឋានពន្ធដារ នឹងបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ករណីស្នើសុំលើកលែងពន្ធ។

សូមបញ្ជាក់ថា ស្ថាប័នត្រូវតែមកចុះបញ្ជីអាជីវកម្មដោយឡែក ក្នុងករណីមានសកម្មភាពសេដ្ឋកិច្ចផ្សេងទៀតក្រៅពីមូលនិធិពីម្ចាស់ជំនួយ ទោះបីជាចំណូលនោះតិចជាងចំណាត់ថ្នាក់/លក្ខខណ្ឌពន្ធតូចក៏ដោយ។ នៅពេលដែលស្ថាប័នមានចំណូលដោយឡែក ច្រើនជាងនេះ អាចចាត់ចូលក្នុងពន្ធតូច ស្ថាប័ននឹងចាត់ចូលក្នុងពន្ធតូចដោយស្វ័យប្រវត្តិ និងអាចអនុវត្តកាតព្វកិច្ច និងបង់ពន្ធបានតែម្តង។

8. សំណួរ (GDT)៖ ការផ្តល់អត្ថប្រយោជន៍បន្ថែមស្មើៗគ្នាទៅដល់បុគ្គលិក (ការពិនិត្យសុខភាព) តើចាំបាច់ត្រូវដាក់លិខិតស្នើសុំទៅពន្ធដារឬទេ?

ចម្លើយ៖ GDT តម្រូវឱ្យដាក់ពាក្យស្នើសុំ ដើម្បីទទួលបានការអនុញ្ញាតការលើកលែងពន្ធអត្ថប្រយោជន៍បន្ថែមនេះ និងត្រូវភ្ជាប់ជាមួយគោលការណ៍ផ្ទៃក្នុងរបស់ស្ថាប័នស្តីពីអត្ថប្រយោជន៍បន្ថែមនេះ។

9. សំណួរ (ACAR)៖ ចំពោះប្រាក់មូលនិធិ ដាក់ក្នុង កូឡោន B ប៉ុន្មានដែរ?

ចម្លើយ៖ ក្នុងកូឡោន (B) Main Business (សកម្មភាពចម្បង) ។ តើសកម្មភាពចម្បង ឬចំណូលចម្បងរបស់អង្គការបានមកពីប្រាក់មូលនិធិម្ចាស់ជំនួយឬទេ? បើត្រូវ ត្រូវដាក់ក្នុងកូឡោន (B)។

10. សំណួរ (ACAR)៖ ស្តង់ដារគណនេយ្យមានពីរប្រភេទគឺ (Cash Basic / Accrual Basic)។ តែសមាគម និងអង្គការមិនមែនរដ្ឋាភិបាលប្រើ Cash Modified ដែលអនុវត្តទាំង Cash Basic និង Accrual Basic ដោយភាគច្រើននៃចំណាយជាសាច់ប្រាក់ និងមានចំណាយតិចតួចជាបង្គរ។ តើស្ថាប័នរបស់ខ្ញុំត្រូវអនុវត្តបែបណាមួយ?

ចម្លើយ៖

សូមបញ្ជាក់ថា៖ ស្តង់ដារគណនេយ្យមានតែពីរប្រភេទទេគឺ មូលដ្ឋានសាច់ប្រាក់/ Cash Basic និងមូលដ្ឋានបង្គរ/Accrual Basic មិនមានស្តង់ដារ Cash Modified នោះទេ។ កន្លងមក NGO ប្រាប់ថា មិនមានស្តង់ណាគណនេយ្យណាមួយប្រើនោះទេ ឥឡូវរដ្ឋាភិបាលមានស្តង់ដារដាក់ឲ្យប្រើស្របតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដែល NGO អាចរើសយក មូលដ្ឋានសាច់ប្រាក់ក៏បាន ឬក៏មូលដ្ឋានបង្គរក៏បាន តែមិនអាចសុំប្រើស្តង់ដារខ្លួនឯង ឬបង្កើតស្តង់ដារខ្លួនឯងសម្រាប់ប្រើនោះទេ។

ACAR មានស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុចំនួន ៣ប្រភេទដាក់ឲ្យជ្រើសរើសសម្រាប់ប្រើប្រាស់មួយណាក៏បាន មានដូចជា៖

- CFRS-NFPEs (Cash basis)
- CIFRS (Accrual basis)
- CIFRS for SME (Accrual basis)

ហើយបើខ្លាចថាជ្រើសរើសស្តង់ដារ Cash basis អាចប៉ះពាល់ដល់ការគណនាពន្ធ ឬការប្រកាសពន្ធតាមប្រព័ន្ធ Tol E-Filing សូមអគ្គនាយកដ្ឋានពន្ធដារធ្វើការបកស្រាយបន្ថែម។

GDT វាអាស្រ័យលើគោលនយោបាយរបស់ស្ថាប័នក្នុងការប្រើប្រាស់ស្តង់ដារគណនេយ្យ (Cash Basic /Accrual Basic)។ បើគោលនយោបាយស្ថាប័នប្រើ Cash Basic នោះការគណនាពន្ធត្រូវយក មូលដ្ឋានសាច់ប្រាក់ (Cash Basic) មកគិត។ តែបើគោលនយោបាយស្ថាប័នប្រើ Accrual Basic នោះការគណនាពន្ធត្រូវផ្អែកលើ Accrual Basic ដូចគ្នា។

11. សំណួរណ (GDT)៖ ការបង់ពន្ធលើប្រាក់បៀវត្សសម្រាប់បុគ្គលិកបរទេស ដែលគាត់បើកប្រាក់បៀវត្សពីបរទេស តើតម្រូវឲ្យបង់ពន្ធលើប្រាក់បៀវត្សឬទេ? បើតម្រូវ តើត្រូវបង់របៀបណា?

ចម្លើយ៖ Resident: របៀបបង់ប្រាក់បៀវត្សអនុវត្តដូចខ្មែរដែរ តែអត្រានៃការបង់សម្រាប់ Non-residentអត្រា ២0%

12. សំណួរ (GDT)៖ ការដាក់លិខិតស្នើសុំលើកលែងពន្ធប្រចាំឆ្នាំ តើលិខិតគំរូពី GDT ទេ? ឬប្រើលិខិតរដ្ឋបាលទូទៅ?

ចម្លើយ៖ GDT មិនមានគំរូលិខិតសម្រាប់ការស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនោះទេ។ អង្គការអាចប្រើលិខិតរដ្ឋបាលរបស់ខ្លួន ដោយមានភ្ជាប់មកជាមួយនូវ៖ លក្ខន្តិកៈរបស់សមាគមឬអង្គការ ហើយយកសំណើ មកដាក់នៅពន្ធដាស្រុកឬខណ្ឌនៃទីតាំងរបស់អង្គការធ្វើការប្រកាសពន្ធ ឬមកដាក់នៅទីស្នាក់ការកណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារក៏បាន។